*<u>គណៈអភិបាល អ្នកតំណាងសមាជិក</u>*

***Layla Gonzalez-Delgado***
***L.A. Care Health Plan,** អ្នកគាំពារសមាជិក*

***Hilda Perez***
***L.A. Care Health Plan,** អ្នកតំណាងសមាជិក*

# កិច្ចប្រជុំពិសេស
# (ក្និចប្រជុំសាលាក្រុងសហគមន៍)

## ថ្ងៃពុធ ទី 23 ខែកញ្ញា ឆ្នាំ 2020
## 10:00 ព្រឹក - 10:45 ព្រឹក

**កិច្ចប្រជុំពិសេស នៃគណៈកម្មាធិការទីប្រឹក្សាប្រតិបត្តិការសហគមន៍, គណៈកម្មាធិការទីប្រឹក្សាប្រចាំភូមិភាគទាំងដប់មួយ ដូចបានរៀបរាប់នៅខាងក្រោម**

## <u>សេចក្តីជូនដំណឹង នៃកិច្ចប្រជុំរួមពិសេស និង របៀបវារៈ</u>

**សេចក្តីជូនដំណឹងត្រូវបានផ្តល់ជូនដោយបញ្ជាក់ថាប្រធានគណៈកម្មាធិការទីប្រឹក្សាប្រតិបត្តិការសហគមន៍ (Executive Community Advisory Committee, ECAC) នៃគណៈអភិបាលរបស់អាជ្ញាធរសុខាភិបាលសម្រាប់គំនិតផ្តួចផ្តើមក្នុងតំបន់សម្រាប់ខោនធី Los Angeles ដែលកំពុងប្រតិបត្តិការ និងធ្វើជំនួញក្នុងនាម L.A. Care Health Plan និងជាប្រធាននៃគណៈកម្មាធិការ ប្រឹក្សាសហគមន៍ប្រចាំតំបន់ទាំង 11 (Regional Community Advisory Committees, RCAC) បានកោះហៅឱ្យមានកិច្ចប្រជុំរួមពិសេសសម្រាប់ ECAC ដែលរួមមាន RCACs នៅតំបន់ 1 (Antelope Valley, Lancaster), 2 (Van Nuys, Pacoima, West Hills, North Hills, Arleta, Sepulveda), 3 (Alhambra, Pasadena, Foothill), 4 (Hollywood, Wilshire, Central L.A, Glendale), 5 (Culver City, Venice, Santa Monica, Malibu, Westchester), 6 (Compton, Inglewood, Lynwood, Watts, Gardena, Hawthorne), 7 (Huntington Park, Bellflower, Norwalk, Cudahy), 8 (Carson, Torrance, San Pedro, Wilmington), 9 (Long Beach), 10 (East L.A, Whittier, Highland Park), 11 (Pomona, El Monte); ដែលត្រូវធ្វើឡើងតាមរយៈសន្និសិទ្ធតាមប្រព័ន្ធទូរគមនាគមន៍ទៅតាមកាលបរិច្ឆេទ និងពេលវេលាដែលបានចង្អុលបង្ហាញខាងលើក្នុងគោលបំណងធ្វើសកម្មភាពអាជីវកម្មដែលមានរាយនៅក្នុងសេចក្តីជូនដំណឹងនៃកិច្ចប្រជុំរួមពិសេស និងរបៀបវារៈនេះ។**

**កិច្ចប្រជុំនេះគ្រាន់តែជាព័ត៍មានប៉ុណ្ណោះ ហើយស្ថាប័នដែលមានរាយនាមក្នុងបញ្ជីនឹងមិនធ្វើសកម្មភាពអ្វីមួយនោះឡើយ។**

**អភិបាលរដ្ឋ California បានដាក់ចេញបទបញ្ជាប្រតិបត្តិលេខ N-25-20 និង N-29-20 ជាបទប្បញ្ញត្តិក្នុងចំណោមបទប្បញ្ញតិផ្សេងៗទៀត ដែលនឹងធ្វើវិសោធនកម្មច្បាប់ Ralph M. Brown។ ដូច្នោះហើយ សាធារណៈជនគួរតែស្តាប់កិច្ចប្រជុំនេះតាមរយៈការសន្និសិទ្ធតាមប្រព័ន្ធទូរគមនាគមន៍ដូចខាងក្រោមៈ**

**<u>ព័ត៍មានក្នុងការហៅចូលសន្និសិទ្ធតាមប្រព័ន្ធទូរគមនាគមន៍</u>**
**លេខសម្រាប់ហៅទូរសព្ទចូលៈ 1-844-907-7272 (ខ្មែរ)**
**លេខកូដចូលប្រើប្រាស់សម្រាប់អ្នកចូលរួមៈ 994 413 241**
**ពាក្យសម្ងាត់នៃកិច្ចប្រជុំៈ (កិច្ចប្រជុំនេះមិនត្រូវការពាក្យសម្ងាត់ទេ)។**

**បន្ទាប់ពីកិច្ចប្រជុំនេះ សមាជិក RCAC ត្រូវបានលើកទឹកចិត្តឱ្យបញ្ជូនយោបល់ ឬសំណួរលើចំណុចរបស់របៀបវារៈជាលាយលក្ខណ៍អក្សរតាមអ៊ីមែលទៅកាន់ រិទ្ធី លឹម (Rithy Lim) តាមរយៈ rithylim@hotmail.com ឬដោយផ្ញើសារជាអក្សរ ឬសារជាសំឡេងទៅកាន់លេខ 559-250-3293។ ការឆ្លើយតបរាល់សំណួរ និងយោបល់នានានឹងត្រូវបានបង្ហោះនៅក្នុងគេហទំព័ររបស់ L.A. Care នៅក្នុងផ្នែក “Special Meeting” (កិច្ចប្រជុំពិសេស)។**

**ត្រូវបង្ហាញសារជាអក្សរ សារជាសំឡេង ឬអ៊ីមែល ប្រសិនបើអ្នកចង់ ឲ្យ គេស្គាល់អត្តសញ្ញាណ ឬចង់លាក់អត្តសញ្ញាណ ហើយក៏ត្រូវបញ្ចូលឈ្មោះនៃចំណុចដែលមតិយោបល់របស់អ្នកទាក់ទងទៅនឹងវា។**

**ប្រសិនបើអ្នកជាបុគ្គលដែលមានពិការភាព ហើយត្រូវការការផ្លាស់ប្តូរ ឬការស្នាក់នៅសមរម្យស្របតាមច្បាប់ស្តីពីជនពិការអាមេរិក សូមទាក់ទងបុគ្គលិកផ្នែកចូលរួម និងផ្សព្វផ្សាយសហគមន៍របស់ L.A. Care (L.A. Care’s Community Outreach & Engagement)**

L.A. Care HEALTH PLAN®

For All of L.A.

មុនកិច្ចប្រជុំចាប់ផ្តើម ដើម្បីទទួលបានជំនួយដោយការផ្ញើសារជាអក្សរទៅលេខ (213) 545-4649 ឬតាមរយៈអ៊ីមែលទៅ coepubliccomments@lacare.org។

## របៀបវារៈ

| | | |
|---|---|---|
| I. សូមស្វាគមន៍ | 5 នាទី | 10:00 ព្រឹក - 10:05 ព្រឹក |
| II. គោលបំណងនៃកិច្ចប្រជុំនៅក្នុងសាលប្រជុំសហគមន៍ | 5 នាទី | 10:05 ព្រឹក - 10:10 ព្រឹក |
| III. បច្ចុប្បន្នភាពស្តីពីអាជីវកម្មរបស់ L.A. Care | 15 នាទី | 10:10 ព្រឹក - 10:25 ព្រឹក |
| IV. បច្ចុប្បន្នភាពស្តីពី COVID-19 | 10 នាទី | 10:25 ព្រឹក - 10:25 ព្រឹក |
| V. បច្ចុប្បន្នភាពស្តីពីគណៈកម្មាធិការដឹកនាំសមធម៌របស់ L.A. Care | 10 នាទី | 10:35 ព្រឹក - 10:45 ព្រឹក |
| VI. ការប្រជុំបន្ទាប់៖ ថ្ងៃពុធទី 18 ខែវិច្ឆិកា ឆ្នាំ 2020 | | |

DRAFT